២- លោក សាម ទីុនសេង បច្ចុប្បន្នប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ មករា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# ២-សេចក្តីសំរេច

## សេចក្តីសំរេចលេខ ០៤ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៩

### ស្តីពីការលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទាន របស់ក្រុមហ៊ុនវិនិយោគចំនួន ០៣

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមស្មារតីអង្គប្រជុំគណៈរដ្ឋមន្ត្រី ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩

### សំរេច

ប្រការ ១ : ត្រូវបានលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទានរបស់ ក្រុមហ៊ុនវិនិយោគចំនួន០៣ ដែលពុំបានគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនិងពុំបានធ្វើសកម្មភាពកាប់ឈើក្នុងដំបន់ព្រៃសម្បទានគឺៈ

១-ក្រុមហ៊ុនផុងស៊ីងដែលមានព្រៃសម្បទានស្ថិតនៅខេត្តក្រចេះ មណ្ឌលគិរី និងព្រះវិហារ មានផ្ទៃដីសរុបចំនួន ៣៧៤.៣៥០ ហិកតា ហើយបានផុតសុពលភាពនៃកិច្ចព្រមព្រៀងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៨ ។

២-ក្រុមហ៊ុនថៃប៊ុនរ៉ុង ដែលមានព្រៃសម្បទានស្ថិតនៅខេត្តក្រចេះ និងមណ្ឌលគិរី មានផ្ទៃដី សរុប ចំនួន ៥១៦.៧០០ ហិកតា ហើយបានផុតសុពលភាពនៃកិច្ចព្រមព្រៀងនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ។

៣-ក្រុមហ៊ុនប៉ាស៊ីហ្វិកប្រាយវូដដែលមានព្រៃសម្បទានស្ថិតនៅខេត្តស្ទឹងត្រែង មានផ្ទៃដីសរុប ចំនួន ១៤.៥៤៧ ហិកតា ហើយបានផុតសុពលភាព ១ឆ្នាំ ។

ប្រការ ២ : ការលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទានរបស់ក្រុមហ៊ុនទាំង ០៣ ដែលមានចែងក្នុងប្រការ១ ខាង លើរាជរដ្ឋាភិបាលមិនមានការទូទាត់សងសំណងណាមួយឡើយ ។

ប្រការ ៣ : ព្រៃសម្បទានដែលដកហូតពីក្រុមហ៊ុនទាំង៣ ខាងលើនេះ ត្រូវរក្សាទុកជាតំបន់ព្រៃបម្រុងទុក ។

ប្រការ ៤ : អនុប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារ ជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត - ក្រុង ដែលពាក់ព័ន្ធ និង ក្រុមហ៊ុនទាំង ៣ ដែលមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ ,ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ០៥ សសរ
## ស្តីពីការបង្កើតមជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យា
## នៅរាជាយស្វ័យយានកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន